ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២១៧

ចុះថ្ងៃទី០៧ខែសីហាឆ្នាំ១៩៩៥

<u>សាលដីកា</u>

លេខ : ២២៥

ចុះថ្ងៃទី១២ខែវិច្ឆិកាឆ្នាំ១៩៩៨

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃ ទី១២ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ដោយមានសមាសភាព ដូចតទៅ :

ឯកឧត្តម ឌិត មុន្ធី ជាប្រធាន

លោក ម៉ែន ស៊ិន ជាចៅក្រមរបាយការណ៍

លោក វៀល បួន ជាចៅក្រម

លោក ស៊ុន ឌឹម ជាចៅក្រម

លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា សេន សុខា

តំណាងមហាអយ្យការ

លោក ម៉ែន សាវឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ២១៦ ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ១៩៥ ចុះថ្ងៃទី ២១ ខែ មិនា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ញ៉ាវ ទោង អាយុ ៥២ឆ្នាំ ជាតិខ្មែរ ភេទប្រុស មុខរបរលក់ដូរ ទីលំនៅភូមិឧត្តម ឃុំព្រែកខ្សាយ "ក" ស្រុកពាមរក៍ ខេត្តព្រៃវែង ។ ឪពុកឈ្មោះ ញ៉ាវ តេង "រ" ម្តាយឈ្មោះ ង៉ែត គ្រួច "រ" ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ផាន ឃិ អាយុ ៣១ឆ្នាំ ជាតិខ្មែរ ភេទស្រី មុខរបរ លក់ដូរ ទីលំនៅភូមិឧត្តម ឃុំព្រែកខ្សាយ "ក" ស្រុកពាមរក៍ ខេត្តព្រៃវែង។ ឪពុកឈ្មោះ តាំង ឈង "ស" ម្តាយឈ្មោះ ហេង តា "ស" ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងទាមទារសំណងការខូចខាត

តាមបណ្តឹងសាទុក្ខលេខ ១០០ ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ១៩៩៨ របស់ លោក ញ៉ាវ ទោង បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ២១៦ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៨ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

៧/.

បាន ឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២១៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៨៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ១៦.៥.៨៥ របស់ដើមចោទថា ខ្លួនបានទិញផ្ទះរបស់ បាវ ទោង នៅជាប់ផ្ទះ បាវ ទោង សព្វថ្ងៃនេះហើយ បាវ ទោង កាលនោះបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់អោយខ្លួនកាលពីថ្ងៃទី ០៦.១១.៨០ មានរដ្ឋអំណាចបញ្ជាក់ត្រឹមត្រូវផង ។

បាន ឃើញសាលក្រមលេខ ០១ "ឃ" ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៨៦ របស់តុលាការខេត្តព្រៃវែងដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១_ ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ១៦.៥.១៩៨៥ របស់ដើមចោទឈ្មោះ ផាន ឃិ ប្ដឹងសុំទាមទារសំណងការខូចខាតផ្ទះចំនួន ០២ តំឡឹង និង ជំនិចិត្ត ១៥តំឡឹងមាស ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_ បង្គាប់អោយឈ្មោះ បាវ ទោង ជាចុងចោទសងដល់ឈ្មោះ ផាន ឃិ ជាដើម_ ចោទនូវសំណងការខូចខាត និង ជំនិចិត្តសរុប ០៣តំឡឹងជាមាសសុទ្ធទឹកដប់ ដើមចោទឈ្មោះ_ ផាន ឃិ ទាមទារលើសពីនេះមិនសេះចោល គិតចាប់តាំងពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ

បើចុងចោទឈ្មោះ បាវ ទោង គ្មានប្រាក់សងគ្រប់ចំនួនទេនោះ ត្រូវរឹបអូសទ្រព្យ_ សម្បត្តិលក់ឡាយឡុងដើម្បីធានាសងដល់ដើមចោទហើយក្នុងករណីរឹបអូសពុំគ្រប់សងប្រាក់ដល់ដើម ចោទ ត្រូវអនុវត្តដាក់គុកបង្ខំរូបកាយតាមការប្ដឹងសុំរបស់ដើមចោទតាមមាត្រា ១២៨ , ១២៩_ ១៣១ នៃច្បាប់ស្ដីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ៥១ក្រ ចុះថ្ងៃទី ០២.០៥.៨២ និងតាមមាត្រា១២១ ១២៨ នៃក្រឹត្យច្បាប់លេខ ៣៨ក្រ ចុះថ្ងៃទី២៨_ ខែ ១០.៨៨ ។

៣_ បង្គាប់អោយចុងចោទបង់ប្រាក់ប្រដាប់ក្ដី : ពន្ធហ៊ុង និង ពន្ធចុះបញ្ជីក្ដី ចំនួន ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ចំនួន ២.០០០៛ ចំណាយក្នុងការស៊ើបអង្កេតអង្កេតចំនួន ៣.០០០៛ សរុប ៧.០០០៛ ប្រាក់ នេះកាត់យកពីប្រាក់ដើមចោទបានបង់រួចហើយ កាលបើមានឧទ្ធរណ៍អោយចុងចោទបង់ប្រាក់ ៧.០០០៛ ទៅដើមចោទវិញ និងអោយបង់ពន្ធសមាមាត្រ ១ គុណ ៣០០ហ៊ុន / ១០០ ស្មើ ៣ហ៊ុនមាស សុទ្ធទឹកដប់ ប្រាក់នេះបង់ចូលថវិការរដ្ឋ ៨០ភាគរយ និង ២០ភាគរយ រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៤_ សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី ។ បើកផ្លូវឧទ្ធរណ៍រយៈពេលពីរខែគិតចាប់តាំងពីថ្ងៃប្រកាសសាលក្រមនេះទៅ ។

បាន ឃើញបណ្ដឹងឧទ្ធរណ៍លេខ ៣៨ ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៨៦ របស់ឈ្មោះ_ បាវ ទោង ដែលប្ដឹងជំទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ ០១ "ឃ" ចុះថ្ងៃទី២១ ខែតុលា_

ឆ្នាំ ១៩៥៦ របស់តុលាការខេត្តព្រៃវែងលើចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីកាលេខ ៣៥ ចុះថ្ងៃទី ០៥ ខែកម្ភៈ ឆ្នាំ ១៩៥៨ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៥.១២.៥៦ របស់ឈ្មោះ ប៉ាវ ទោង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២_ តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១ "ឃ" ចុះថ្ងៃទី២១.១០.៥៦ របស់តុលាការខេត្តព្រៃវែង ទុកជាបានការពេញទាំងមូល ។

៣_ ទឹមអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធចុះបញ្ជាក្តី និង ពន្ធតែមចំនួន ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ចិចប្រាក់ចំនួន ៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛ លើអាជ្ញាគរតុលាការ ៥.០០០៛ ។

៤_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ កំបាំងមុខគូក្តី បើកផ្លូវប្តឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់ចុះថ្ងៃទី ២៣.៣.៥៨ របស់លោក ប៉ាវ ទោង ដែលប្តឹងជំទាស់នឹងសាលក្រមលេខ ៣៥ ចុះថ្ងៃទី០៥.០២.៥៨ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីកាលេខ ២១៦ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ ១៩៥៨ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលបណ្តឹងទាស់ចុះថ្ងៃទី ២៣.៣.៥៨ របស់ឈ្មោះ ប៉ាវ ទោង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

២_ តម្កល់សាលដីកាលេខ ៣៥ ចុះថ្ងៃទី ៥.២.៥៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១០០ ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ១៩៥៨ របស់លោក ប៉ាវ ទោង ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ១៩៥៨ របស់ឈ្មោះ ប៉ាង ទោង ។

បានឃើញសារណាតបចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ១៩៥៨ របស់ឈ្មោះដាន ឆិ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីកាសាលាឧទ្ធរណ៍

ដែលបានសំរេចមកនេះមានការខុសឆ្គងទាំងស្រុងទៅនឹងគតិច្បាប់ ។

ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ព្រាំ ទោង ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខដែលបានឆ្លើយនៅពេលសវនាការថា : នៅថ្ងៃទី ១៥.៣.៨៥ នាង ផាន ឈិ គាត់បាននិយាយថា ខ្លួនសាងសង់ផ្ទះប៉ះពាល់ផ្ទះរបស់គាត់ តែនៅពេលខ្លួនសាងសង់នាង ផាន ឈិ បានយល់ព្រមហើយព្រមទាំងផ្តិតមេដៃអោយខ្លួននៅចំពោះមុខឃុំគិមស្រុកទៀតផង ហើយមុនសាងសង់ខ្លួនក៏បានសុំសុរិយោដី និង បានសុំអ្នកជិតខាង ហើយអ្នកជិតខាងក៏យល់ព្រមដែរ ដីដែលខ្លួនទិញពីលោកមេភូមិគឺខ្លួនធ្វើតែត្រឹមទំហំប៉ុនដីដែលខ្លួនទិញទេ ។ ឯសាលាឧទ្ធរណ៍គាត់មានយោបល់ថា គាត់កាត់តាមខេត្ត ទោះបីមានស្នាមមេដៃក៏ដោយ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ផាន ឈិ ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខដែលបានឆ្លើយនៅពេលសវនាការថា : បានជាខ្លួនប្តឹងព្រោះឈ្មោះនេះបានរំលោភលើកម្មសិទ្ធិស្របច្បាប់របស់ខ្លួន នៅថ្ងៃទី០៦ ឆ្នាំ១៩៨០ ខ្លួនបានទិញផ្ទះពីឈ្មោះ ព្រាំ ទោង តែគាត់បែរជានិយាយថាលក់ផ្ទះអត់លក់ដីសុំតុលាការជួយពិចារណាអោយខ្លួនផង ។ ហើយខ្លួនបានធ្វើអោយផ្ទះរបស់ខ្លួនអត់ជញ្ជាំង តើខ្លួនទិញផ្ទះរបៀបនេះឬ ? ដែលខ្លួនបានទិញយ៉ាងស្របច្បាប់ និង មានសាក្សីដឹងឮទៀតផង ។ ការផ្សះផ្សាគឺជារឿងផ្សេង គឺ មិនមែនជារឿងជាមួយគ្នាទេ ខ្លួនសំណូមពរសុំលោក ព្រាំ ទោង រកិលជញ្ជាំងលើសចំណុចសូន្យមកនៅត្រឹមចំនុចសូន្យ សុំអោយសងជម្ងឺចិត្ត ១៧តំលឹង និង បញ្ឈប់ការប្រមាថមើលងាយលើគ្រួសាររបស់ខ្លួន ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ព្រាំ ទោង ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខដែលបានឆ្លើយនៅពេលសវនាការថា : ផ្ទះរបស់ខ្លួន ៥ម ៤តឹក គឺខ្លួនសង់តែត្រឹមប៉ុណ្ណោះទេ ខ្លួនអារតែដំបូលផ្ទះរបស់ខ្លួនទេ ខ្លួនមិនមែនអារដំបូលផ្ទះរបស់អ្នកឯងទេ ។ ខ្លួនមិនបានមើលងាយមើលថោកទេ ព្រោះនាង ផាន ឈិ បានផ្តិតមេដៃអោយខ្លួនសាងសង់ទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ១០០ ចុះថ្ងៃទី១២.៥.៨៨ របស់លោក-ព្រាំ ទោង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។
- យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍ ក៏ដូចតុលាការខេត្តព្រៃវែងដែរ

ដែលសំរេចអោយចុងចម្លើយសងការខូចខាតទៅដើមចោទនោះជាការភ័ន្តច្រឡំពីព្រោះ ថា តាមកំណត់ហេតុចុះថ្ងៃទី ០៥.៣.៩៥ នៅឃុំគិតមិ៍ស្រុកគូភាគីបានព្រមព្រៀងឯកភាពគ្នា អោយចុងចម្លើយជួសជុលដំបូលអោយដើមចោទប្រាកដមែន ។ ម្យ៉ាងទៀតក្នុងការកំណត់អំពី បរិមាណសំណងនោះ តុលាការថ្នាក់ក្រោមពុំបានអោយអង្គភាពជំនាញធ្វើការវាយតម្លៃ អោយបានច្បាស់លាស់ឡើយ ។

- យល់ឃើញថា : ការលើកឡើងរបស់គូភាគីអំពីទំហំដីដែលត្រូវសង់ផ្ទះនោះ តុលាការកំពូលពុំមានសិទ្ធិពិចារណាឡើយ ពីព្រោះអ្នកស្រី ផាន ឆៃ ពុំបានប្តឹងឧទ្ធរណ៍ពីការ ដែលតុលាការថ្នាក់ក្រោមពុំបានសំរេចពីបណ្តឹងរបស់អ្នកស្រីឡើយ ។

- យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខ ២១៦ ចុះថ្ងៃទី ១២.៥.៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ១០០ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់លោក ប៉ាវ ទោង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ២១៦ ចុះថ្ងៃទី ១២ ខែ ឧសភា- ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២១៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោក ប៉ាវ ទោង បាន បង់រួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,
- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប១៩.០០០រៀល។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១២ - ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ។